ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង : ១១/០៩ —ឡេតគី ហ្គាមេន**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៩**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: **ឈីវ ភិរម្យ**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: **អាន វីរៈ**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: **គង់ ផល្លះ**

## ភាគីនៃវិវាទ

១- **ភាគីនិយោជក**

ឈ្មោះ : **ក្រុមហ៊ុន ឡេតគី ហ្គាមិន ហ្វាក់តូរី (ខេមបូឌា) អិលធីឌី**

អាសយដ្ឋាន : ភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៧២៧ ៣០១ ទូរសារ : គ្មាន

តំណាងភាគីនិយោជក :

១- កញ្ញា វ៉ា ចិន្តា ប្រធានរដ្ឋបាល

២- **ភាគីកម្មករនិយោជិត**

**ឈ្មោះ : សហព័ន្ធសហជីពកម្មករកម្ពុជា-សហជីពកម្មករនិយោជិត នៃរោងចក្រ ឡេតគី ហ្គាមេន**

អាសយដ្ឋាន : ផ្ទះលេខ ៧៨៨ ផ្លូវ ៤៧៤ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ

លេខទូរស័ព្ទ : ០១៧ ៦១៦ ៥៩៨ លេខទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

១- លោក ហ៊ូរ ពៅ មន្ត្រីសហព័ន្ធសហជីពកម្មករកម្ពុជា



មជ្ឈមណ្ឌលភ្នំពេញ អគារ A បន្ទប់លេខ ៣៣១ វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ : ០២៣ ២២
Phnom Penh Center (A), Room 331, Sothearos Blvd, Sangkat Tonle Basak, Khan Chamkar Morn, Phom Penh · Tel/Fax: 023
Email: secretariat@arbitrationcouncil.org· Website: www.arbitrationcouncil.org

២- លោក កាន់ យឿង ប្រធានសហជីពកម្មករនិយោជិត នៃរោងចក្រ ត្លេតភី

៣- លោកស្រី ជា យ៉ុម អនុប្រធានសហជីពកម្មករនិយោជិត នៃរោងចក្រ ត្លេតភី

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិត នៅតែទាមទារឱ្យក្រុមហ៊ុនផ្តល់ការឈប់សម្រាកប្រចាំឆ្នាំបន្ថែមមួយថ្ងៃក្នុងមួយឆ្នាំ ដល់កម្មករនិយោជិតណាដែលធ្វើការបានរាល់ ០៣ ឆ្នាំម្តង (ឧទាហរណ៍ : ធ្វើការបាន ០៣ ឆ្នាំ ទទួលការឈប់សម្រាកប្រចាំឆ្នាំចំនួន ១៩ ថ្ងៃ, ០៦ ឆ្នាំ ទទួលបាន ២០ ថ្ងៃ, ០៩ ឆ្នាំ ទទួលបាន ២១ ថ្ងៃ។ល។) ដោយឡែកភាគីនិយោជកបញ្ជាក់ថា នាយកក្រុមហ៊ុនផ្តល់ការឈប់សម្រាកប្រចាំឆ្នាំនេះ ជូនកម្មករនិយោជិត បានត្រឹមតែ ២០ ថ្ងៃប៉ុណ្ណោះ ទោះបីជាកម្មករនោះបានធ្វើការលើសពី ០៦ ឆ្នាំឡើងទៅក៏ដោយ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាស លេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៧៦/០៧ កកបវ./ប្រក ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៧ (អាណត្តិទី៥) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ០៤០ ក.ប/អក/វ.ក ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៩ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០៩។

## សវនាការ និង សង្ខេបនីតិវិធីមុនពេលក្រុមប្រឹក្សាអាជ្ញាកណ្តាល

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈមណ្ឌលភ្នំពេញ អគារ A វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :** ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០០៩ (វេលាម៉ោង ០៩:៣០ នាទី ព្រឹក) ។

6

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០៩ នាយកដ្ឋានវិវាទការងារ បានទទួលបណ្តឹងរបស់កម្មករនិយោជិត នៃក្រុមហ៊ុន គ្លេតភី ហ្គាមិន ហ្វាក់តូរី (ខេមបូឌា) មួយច្បាប់ ចុះថ្ងៃទី ១៦ មករា ឆ្នាំ ២០០៩ ទាមទារឱ្យក្រុមហ៊ុន បូកបន្ថែមការឈប់សម្រាកប្រចាំឆ្នាំចំនួន ០១ ថ្ងៃក្នុងមួយឆ្នាំ ដល់កម្មករនិយោជិត ដែលធ្វើការចាប់ពី ០៣ ឆ្នាំឡើងទៅ។ បន្ទាប់ពីបានទទួលបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារ បានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងារនេះ ប៉ុន្តែមិនបានទទួលលទ្ធផលសះជាទេ លើការទាមទារទាំងអស់ចំនួន ០១ ចំណុច។ ចំណុចមិនសះជាចំនួន ០១ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០៩។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញភាគីក្រុមហ៊ុន និង ភាគីកម្មករនិយោជិតមកសវនាការ និង ធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០១ ចំណុចនេះ នៅថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០០៩ (វេលាម៉ោង ០៩:៣០ នាទី ព្រឹក)។ ភាគីទាំងពីរ មានវត្តមាន តាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានព្យាយាមធ្វើការផ្សះផ្សាលើចំណុចមិនសះជាចំនួន ០១ ចំណុចនេះ ប៉ុន្តែមិនបានទទួលលទ្ធផលសះជាទេ។ ហេតុនេះហើយ នៅក្នុងរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ធ្វើការពិចារណាលើចំណុចវិវាទនេះ ដោយផ្អែកលើ ភស្តុតាង និង ហេតុផល ដូចខាងក្រោម:

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន**

**ឯកសារ ឧត្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក :**

១- លិខិតផ្ទេរសិទ្ធិរបស់នាយកក្រុមហ៊ុនជូន កញ្ញា វ៉ា ចិន្តា ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០៩។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :**

១- វិញ្ញាបនប័ត្រចុះបញ្ជិកា សហជីពកម្មករនិយោជិត នៃរោងចក្រ គ្លេតភី ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០១។

២- លិខិតរបស់ប្រធាននាយកដ្ឋានអធិការកិច្ចការងារ ជូនទៅ ប្រធានសហជីពកម្មករនិយោជិត នៃរោងចក្រ គ្លេតភី ស្តីពីការស្នើសុំទទួលស្គាល់ថ្នាក់ដឹកនាំសហជីព អាណត្តិទី២ លេខ ១៦៩ សកបយ/អក ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៤។

៣- លិខិតរបស់ប្រធាននាយកដ្ឋានវិវាទការងារ ជូនទៅ ប្រធានសហជីពកម្មករនិយោជិត នៃរោងចក្រ គ្លែតភី ស្តីពីការស្នើសុំទទួលស្គាល់ថ្នាក់ដឹកនាំសហជីព អាណត្តិទី៣ លេខ ១៧៦០ ក.ក.ប.វ/អក/វក. ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៦។

៤- លិខិតរបស់ប្រធាននាយកដ្ឋានវិវាទការងារ ជូនទៅ ប្រធានសហជីពកម្មករនិយោជិត នៃរោងចក្រ គ្លែតភី ស្តីពីការស្នើសុំទទួលស្គាល់ថ្នាក់ដឹកនាំសហជីព អាណត្តិទី៤ លេខ ១៣៨៤ កប/អក/វក ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០៨។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន គ្លែតភី លេខ ០៤០ ក.ប/អក/វ.ក ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៩។

២- កំណត់ហេតុដោះស្រាយវិវាទការងាររួមរបស់ក្រុមហ៊ុន គ្លែតភី ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០៩។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ០៥៩ កប/អក/វក/លកអ. ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០៩។

២- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ០៥៨ កប/អក/វក/លកអ. ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០៩។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យឯកសារផ្សេងៗដែលបានដាក់ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល
- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :**

- រោងចក្រ គ្លែតភី ហ្គាមិន ហ្វាក់តូរី មានជួលកម្មករនិយោជិត សរុបប្រហែល ៣០០០ នាក់។
- សហជីពកម្មករនិយោជិតរោងចក្រ គ្លីតភី ដែលជាដើមបណ្តឹងក្នុងរឿងនេះ។ សហជីពនេះទទួលបានវិញ្ញាបនប័ត្រចុះបញ្ជិកា នៅថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០១។
- ភាគីទាំងពីរកំពុងចរចាអនុសញ្ញារួម ហើយចំណុចវិវាទនេះ ជាចំណុចមួយនៅការចរចាអនុសញ្ញារួម
- កម្មករនិយោជិតដែលធ្វើការលើសពី ០៣ឆ្នាំ មានចំនួនលើសពី ១០០០ នាក់។

- កម្មករនិយោជិតដែលធ្វើការលើសពី ០៦ ឆ្នាំ មានចំនួនលើសពី ១០០ នាក់
- កម្មករនិយោជិតដែលធ្វើការលើសពី ១០ ឆ្នាំមានចំនួនជាង ១០ នាក់។
- នៅក្នុងក្រុមហ៊ុននេះបានអនុវត្តការឈប់សម្រាកប្រចាំឆ្នាំ ដូចខាងក្រោម:

| **ចំនួនឆ្នាំធ្វើការ** | **ការឈប់សម្រាកប្រចាំឆ្នាំរបស់ក្រុមហ៊ុន** |
|---|---|
| ឆ្នាំទី១ | ១៨ថ្ងៃ |
| ឆ្នាំទី២ | ១៨ថ្ងៃ |
| ឆ្នាំទី៣ | ១៩ថ្ងៃ |
| ឆ្នាំទី៤ | ១៩ថ្ងៃ |
| ឆ្នាំទី៥ | ១៩ថ្ងៃ |
| ចាប់ពីឆ្នាំទី៦ឡើងទៅ | ២០ថ្ងៃ |

- កម្មករទាមទារឱ្យក្រុមហ៊ុនបូកបន្ថែមការឈប់សម្រាកប្រចាំឆ្នាំចំនួន ០១ ថ្ងៃ ដល់កម្មករនិយោជិតណាដែលធ្វើការ ចាប់ពី ០៣ ឆ្នាំឡើងទៅ ដោយផ្អែកតាមមាត្រា ១៦៦ នៃច្បាប់ស្តីពីការងារ ព្រោះក្រុមហ៊ុនបានកំណត់ការឈប់សម្រាកប្រចាំឆ្នាំត្រឹមតែ ២០ថ្ងៃ ចាប់ពីឆ្នាំទី៦ឡើងទៅ។
- ក្រុមហ៊ុនមិនឯកភាពទេ មូលហេតុគឺច្បាប់ការងារមិនច្បាស់លាស់ ហើយទុកឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចលើករណីនេះ។

## **ហេតុផលនៃសេចក្តីសម្រេច**

ចំណុចបញ្ហានៅក្នុងសំណុំរឿងនេះ កើតឡើងដោយសារភាគីទាំងពីរមានការយល់ឃើញខុសគ្នា អំពីមាត្រា ១៦៦ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីការងារ គឺក្រុមហ៊ុនយល់ថា ច្បាប់ស្តីពីការងារមិនច្បាស់លាស់។ ចំណែកឯភាគីកម្មករនិយោជិត បានទាមទារឱ្យក្រុមហ៊ុនអនុវត្តតាមមាត្រា ១៦៦ នៃច្បាប់ស្តីពីការងារ ដោយបន្ថែមការឈប់សម្រាកមួយថ្ងៃរាល់ ០៣ ឆ្នាំ ព្រោះក្រុមហ៊ុនបានកំណត់ការឈប់សម្រាកប្រចាំឆ្នាំត្រឹមតែ ២០ថ្ងៃ ចាប់ពីឆ្នាំទី ០៦ ឡើងទៅ។ ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា លើការទាមទារនេះ ដូចខាងក្រោម:

មាត្រា ១៦៦ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការងារបានចែងថា " *លើកលែងតែមានបញ្ញត្តិក្នុងអនុសញ្ញារួម ឬកិច្ចសន្យាការងាររៀងខ្លួន ដែលផ្តល់អត្ថប្រយោជន៍ច្រើនជាងនេះ កម្មករនិយោជិតទាំងអស់ត្រូវមានសិទ្ធិឈប់សម្រាកប្រចាំឆ្នាំមានប្រាក់ឈ្នួលដែលនិយោជកត្រូវចេញឱ្យ។ ឯថ្ងៃឈប់សម្រាកនោះ ត្រូវគិតជាថ្ងៃធ្វើការធម្មតាមួយថ្ងៃកន្លះ ក្នុងរយៈពេលធ្វើការមួយខែដាច់។* "

ផ្អែកលើខ្លឹមសារនៃ មាត្រា ១៦៦ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការងារ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិតទាំងអស់ត្រូវមានសិទ្ធិឈប់សម្រាកប្រចាំឆ្នាំមានប្រាក់ឈ្នួល ដែលនិយោជកត្រូវចេញឱ្យចំនួន ១៨ ថ្ងៃ ក្នុងមួយឆ្នាំ ឬ មួយថ្ងៃកន្លះក្នុងរយៈពេលធ្វើការមួយខែជាប់។

មាត្រា ១៦៦ កថាខណ្ឌទី៤ ចែងថា *"ថិរវេលានៃការឈប់សម្រាក ដែលបានកម្រិតដូចខាងលើនេះ ត្រូវបន្ថែមឱ្យកម្មករនិយោជិតតាមអតីតភាពរបស់ខ្លួនក្នុងសហគ្រាសដោយត្រូវបន្ថែមមួយថ្ងៃ "ថ្ងៃធ្វើការ" ក្នុងរយៈពេលធ្វើការបានបីឆ្នាំ។"*

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយ មាត្រា ១៦៦ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីការងារនេះថា *"កម្មករនិយោជិតមានសិទ្ធិទទួលបានការឈប់សម្រាកបន្ថែមមួយថ្ងៃ សម្រាប់រយៈពេលបំរើការងារ ០៣ ឆ្នាំ ដល់សហគ្រាស។ មានន័យថា មាត្រា ១៦៦ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីការងារខាងលើនេះ ផ្តល់សិទ្ធិឱ្យកម្មករនិយោជិតទទួលបានការឈប់សម្រាកចំនួន ១៩ ថ្ងៃ នៅឆ្នាំទី៤ ចំនួន ២០ ថ្ងៃ នៅឆ្នាំទី៧ ចំនួន ២១ ថ្ងៃ នៅឆ្នាំទី១០... ។ល។"* (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ *៦២/០៤-អ៊ីស៊ីន ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី៨ លេខ ៦៨/០៥-ហ្គោលឌីដា លេខ៨១/០៥-ស៊ុខ ព្រីម ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី២ លេខ ៣៣/០៧-ហ្គោល ហ្វេម ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី៥ និងលេខ ២៣/០៨-អ៊ីម និង វ៉ី ១ ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី៣* ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របទៅលើការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅក្នុងសំណុំរឿងមុនៗដែរ គឺ កម្មករនិយោជិតមានសិទ្ធិទទួលបានការឈប់សម្រាកបន្ថែមចំនួន ០១ ថ្ងៃនៃថ្ងៃធ្វើការ នៅរៀងរាល់ពេលដែលកម្មករនិយោជិតបានបំរើការងារបាន ០៣ ឆ្នាំ ម្តងៗ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការកើនឡើងនៃអតីតភាពការងាររបស់កម្មករនិយោជិត នៅក្នុងក្រុមហ៊ុនត្រូវបានលើកទឹកចិត្តជាមួយនឹងការផ្តល់ការឈប់សម្រាកបន្ថែម។ ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ក្រុមហ៊ុនមិនមានសិទ្ធិកំណត់ការផ្តល់ការឈប់សម្រាកប្រចាំឆ្នាំត្រឹម ២០ ថ្ងៃ ក្នុងមួយឆ្នាំ សម្រាប់កម្មករនិយោជិតដែលមានអតីតភាព ចាប់ពី ០៦ ឆ្នាំឡើងទៅនោះទេ។

សរុបសេចក្តីមក ក្រុមប្រឹក្សាអាជ្ញាកណ្តាល យល់ឃើញថា ក្រុមហ៊ុនត្រូវតែបន្ថែមការឈប់សម្រាកប្រចាំឆ្នាំ ដោយមានប្រាក់ឈ្នួលឱ្យកម្មករនិយោជិត តាមអតីតភាពរបស់ពួកគេក្នុងសហគ្រាស ដោយត្រូវបន្ថែមមួយថ្ងៃ "ថ្ងៃធ្វើការ" ក្នុងរយៈពេលធ្វើការបានបីឆ្នាំ ផ្អែកតាមខ្លឹមសារ នៃមាត្រា ១៦៦ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីការងារ។

យោងតាមការបង្ហាញពីអង្គហេតុ អង្គច្បាប់ និង ហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច :

## សម្រេច និង បង្គាប់

បង្គាប់ឱ្យក្រុមហ៊ុនផ្តល់ការឈប់សម្រាកប្រចាំឆ្នាំឱ្យកម្មករនិយោជិត តាមអតីតភាពការងារ របស់កម្មករនិយោជិតក្នុងសហគ្រាស ដោយត្រូវបន្ថែមមួយថ្ងៃ "ថ្ងៃធ្វើការ" ក្នុងរយៈពេលធ្វើការបានបីឆ្នាំ។

**ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **ឈឹម ភិរម្យ**

ហត្ថលេខា: ----------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **អាន វីរៈ**

ហត្ថលេខា: ----------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : **គង់ ផល្លៈ**

ហត្ថលេខា: ----------------------------------